ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.....៤០៩១.......អពដ

ថ្ងៃអង្គារ ០៤រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២១

# សេចក្តីណែនាំ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មបន្តបន្ទាប់ និងប្រកាសលេខ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ស្តីពីពន្ធលើប្រាក់ចំណូល អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធ លោក-លោកស្រីជាអភិបាល បណ្ណាធិការ កម្មសិទ្ធិករសហគ្រាស ភ្នាក់ងារសេវាកម្មពន្ធដារ និងប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ឱ្យបានជ្រាបថា ថ្មីៗនេះអគ្គនាយកដ្ឋានពន្ធដារបានធ្វើការកែសម្រួលទម្រង់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ និងបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (Tax on Income - ToI E-Filing)។ ស្របពេលជាមួយគ្នានេះដែរ ក្នុងគោលដៅជាជំនួយដល់អ្នកជាប់ពន្ធក្នុងការរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ និងស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ អគ្គនាយកដ្ឋានពន្ធដារ បានធ្វើបច្ចុប្បន្នភាព**សេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ**ផងដែរ **(ដូចមានភ្ជាប់មកជាមួយនូវសេចក្តីណែនាំនេះ)** ដែលមានខ្លឹមសារចែកចេញជា ៥ផ្នែកសំខាន់ៗដូចខាងក្រោម៖

១). របៀបបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

២). ព័ត៌មានត្រូវបំពេញនៅក្នុងលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

៣). ព័ត៌មានត្រូវបំពេញក្នុងតារាងកែតម្រូវក្រៅគណនេយ្យ

៤). ព័ត៌មានត្រូវបំពេញក្នុងឧបសម្ព័ន្ធ

៥). ការប្រើប្រាស់អត្រាប្តូរប្រាក់ក្នុងការរៀបចំលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមជឿជាក់ថាសេចក្តីណែនាំសម្រាប់បំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំនេះ នឹងជួយលោក-លោកស្រីជាអភិបាល បណ្ណាធិការ កម្មសិទ្ធិករសហគ្រាស ភ្នាក់ងារសេវាកម្មពន្ធដារ និងប្រធានសមាគមនិងអង្គការក្រៅរដ្ឋាភិបាល ដែលជាអ្នកជាប់ពន្ធធំ និងមធ្យម អាចបំពេញលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំបានត្រឹមត្រូវជាក់ជាមិនខានឡើយ។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh